ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
# ស្តីពី
# ទីភ្នាក់ងារជ្រើសរើសឯកជនដែលបានទទួលការអនុញ្ញាតឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅតំបន់រដ្ឋបាលពិសេសហុងកុង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា ទីភ្នាក់ងារជ្រើសរើសឯកជនដែលបានទទួលការអនុញ្ញាតឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅតំបន់រដ្ឋបាលពិសេសហុងកុងមានចំនួន ២ ដូចមានរាយនាមក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រុមហ៊ុន | អាសយដ្ឋាន | លេខទូរសព្ទ |
|---|---|---|---|
| 1 | **ហ្គូដ យ៉ប មេន ផៅវ័រ អ៊ិនធើណេសិនណល ខ.ក**<br>GOOD JOB MAN POWER INTERNATIONAL CO., LTD. | ផ្ទះលេខ១១០A ក្រុម៧ ភូមិឫស្សី១ សង្កាត់ស្ទឹងមានជ័យ៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ | 012 742 100<br>015 742 100<br>061 448 880 |
| 2 | **ផេស៊ីហ្វិក អ៊ីមផ្លយមិន អេជេន ខ.ក**<br>PACIFIC EMPLOYMENT AGENT CO., LTD. | ផ្ទះលេខ១៥H ផ្លូវលេខ៣៧១ ភូមិត្រពាំង៣ សង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ | 016 770 870<br>077 770 870<br>066 770 870 |

សាធារណជនដែលមានបំណងស្វែងរកការងារធ្វើនៅតំបន់រដ្ឋបាលពិសេសហុងកុង អាចចុះឈ្មោះស្វែងរកការងារដោយទាក់ទងផ្ទាល់ជាមួយទីភ្នាក់ងារជ្រើសរើសឯកជនដែលមានឈ្មោះក្នុងបញ្ជីខាងលើ ឬបញ្ជីបច្ចុប្បន្នភាពទីភ្នាក់ងារជ្រើសរើសឯកជននៅលើគេហទំព័រផ្លូវការរបស់ក្រសួងតាមរយៈតំណភ្ជាប់ www.mlvt.gov.kh ។

អ្នកស្វែងរកការងារធ្វើនៅក្រៅប្រទេស ក៏អាចចុះឈ្មោះស្វែងរកការងារតាមរយៈកម្មវិធីទូរសព្ទដៃរបស់ក្រសួង "MLVT Services" ឬតាម "បញ្ជរសេវាសាធារណៈចល័តរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ" ដែលមាននៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មជ្ឈមណ្ឌលការងារ សាខាបេឡាជាតិសន្តិសុខសង្គម គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ផ្សារទំនើបអេអនទាំង៣សាខា ឬស្តែនយូអរកូដ "ការងារក្រៅប្រទេស" និងតាមដានដំណើរការឯកសាររបស់ខ្លួន ចាប់ពីដំណាក់កាលចុះឈ្មោះស្វែងរកការងារតាមរយៈតំណភ្ជាប់ https://tracking.ocwc.co/ ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ :(០២៣)៨៨២៧៦៩

ទីភ្នាក់ងារជ្រើសរើសឯកជនដែលមិនមានឈ្មោះក្នុងបញ្ជីខាងលើនេះ ជាទីភ្នាក់ងារជ្រើសរើសឯកជនខុសច្បាប់ ដែលត្រូវប្រឈមនឹងការផ្តន្ទាទោសតាមច្បាប់ជាធរមាន។ ក្នុងករណីទទួលព័ត៌មានថាមានទីភ្នាក់ងារជ្រើសរើសឯកជនដែលមិនមានឈ្មោះក្នុងបញ្ជីខាងលើ ធ្វើសកម្មភាពផ្សព្វផ្សាយជ្រើសរើសពលករទៅធ្វើការនៅតំបន់រដ្ឋបាលពិសេសហុងកុង សូមរាយការណ៍ជាបន្ទាន់មកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈប្រព័ន្ធឆ្លើយតបបន្ទាន់ ១២៩៧ ឬក្រុមតេឡេក្រាម "សម្រាប់ ពលករទេសន្តរប្រវេសន៍" តាមតំណរភ្ជាប់ https://t.me/KhmerMigrantWorker ឬប្រអប់បណ្តឹងអនាមិកដោយស្កេនឃ្យូអរកូដខាងក្រោម ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំង២៥ រាជធានី ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសអ្នកដែលមានបំណងស្វែងរកការងារធ្វើនៅតំបន់រដ្ឋបាលពិសេសហុងកុង និងបណ្តាសារព័ត៌មានទាំងអស់ជ្រាបជាព័ត៌មាន។

ថ្ងៃ ពុធ ៧រោច ខែ ទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ សីហា ឆ្នាំ២០២៦

"MLVT Services" "ការងារក្រៅប្រទេសស្របច្បាប់" "សម្រាប់ ពលករទេសន្តរប្រវេសន៍" "បណ្តឹងអនាមិក"